**Declassified to Public**
**12 April 2013**

លេខ / No: D402

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
**Royaume du Cambodge**
**Nation Religion Roi**

**Kingdom of Cambodia**
**Nation Religion King**

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des Tribunaux cambodgiens

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 06 / 09 / 2010
ម៉ោង (Time/Heure): 10:00
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: Ratanak

**លេខសំណុំរឿង: ០០២/១៩-០៩-២០០៧/អ.វ.ត.ក.--ក.ស.ច.ស.**

**ការិយាល័យសហចៅក្រមស៊ើបអង្កេត**

**Office of the Co-Investigating Judges**
**Bureau des co-juges d'instruction**

ចំពោះមុខ ៖ **ចៅក្រម យូ ប៊ុនឡេង**

**ចៅក្រម Marcel LEMONDE**

កាលបរិច្ឆេទ ៖ **ថ្ងៃទី ០៣ ខែកញ្ញា ឆ្នាំ២០១០**

ភាសា ៖ **ខ្មែរ/បារាំង**

ចំណាត់ថ្នាក់ឯកសារ ៖ **សម្ងាត់**

---

# ដីកាសម្រេច បដិសេធពាក្យសុំមោឃភាពធ្វើឡើងដោយ អៀង សារី D381និង D387

---

**សហព្រះរាជអាជ្ញា**

លោកស្រី ជា លាង

លោក Andrew CAYLEY

**ជនត្រូវចោទ**

នួន ជា
អៀង សារី
អៀង ធីរិទ្ធ
ខៀវ សំផន
កាំង ហ្គេកអ៊ាវ ហៅ ឌុច

**មេធាវីដើមបណ្តឹងរដ្ឋប្បវេណី**

នី ចាន់ឌី
គង់ ពិសី
យុង ផានិត
ម៉ុច សុវណ្ណារី
ជេត វណ្ណលី
វ៉ែន ពៅ
ឡោ ជុនធី
ហុង គីមសួន
គីម ម៉េងឃី
ស៊ិន សុវ៉ន
ពេជ អង្គ
Silke STUDZINSKY
Françoise GAUTRY
Isabelle DURAND
Ferdinand Djammen-Nzepa
Emmanuel ALTIT
Emmanuel JACOMY
Phillipe CANONNE
Elizabeth Rabesandratana
Mahdev MOHAN
Olivier BAHOUGNE
Martine JACQUIN
Annie DELAHAIE
Fabienne TRUSSES-NAPROUS
Patrick BAUDOIN
Lyma Thuy Nguyen
Marie Guiraud
Laure DESFORGES
Christine MARTINEAU
Pascal AUBOIN
Barnabe NEKUIE
Nicole DUMAS
Daniel LOSQ
Julien RIVET

**មេធាវីការពារក្តី**

សុន អរុណ Michiel PESTMAN
Victor KOPPE
អាង ឧត្តម Michael G.KARNAVAS
ផាត់ ពៅស៊ាង Diana ELLIS
ស សុវាន Jacques VERGÈS
Philippe GRÉCIANO
ការ សាវុត្ថ

ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date /Date de certification):
06-Sep-2010, 10:10
Kauv Keoratanak

00598433



យើង **យូ ប៊ុនឡេង** និង Marcel LEMONDE (ម៉ាសែល ឡឺម៉ុង) សហចៅក្រមស៊ើបអង្កេតនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (“អ.វ.ត.ក.”)

បានឃើញច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញ ចុះថ្ងៃទី ២៧ ខែតុលា ឆ្នាំ ២០០៤ (“ច្បាប់ស្តីពី អ.វ.ត.ក”)

បានឃើញវិធាន ២១ វិធាន ៤៨ និង វិធាន ៧៦ នៃវិធានផ្ទៃក្នុងនៃ អ.វ.ត.ក (“វិធានផ្ទៃក្នុង”)

បានឃើញការស៊ើបសួរ លើឈ្មោះ **អៀង សារី** និង **ជនដទៃ** ដែលត្រូវបានដាក់ឲ្យស្ថិតក្រោមការពិនិត្យចំពោះ **បទឧក្រិដ្ឋប្រឆាំងនឹងមនុស្សជាតិ ការបំពារបំពានធ្ងន់ធ្ងរលើអនុសញ្ញាក្រុងហ្សឺណែវ ចុះថ្ងៃទី ១២ ខែ សីហា ឆ្នាំ ១៩៤៩ បទប្រល័យពូជសាសន៍ ការធ្វើមនុស្សឃាត ការធ្វើទារុណកម្ម ការវាយប្រហារលើសាសនា** បទល្មើសដែលមានចែង និងផ្តន្ទាទោស តាមមាត្រា៣ មាត្រា៤ មាត្រា៥ មាត្រា៦ មាត្រា២៩ (ថ្មី) និងមាត្រា៣៩ (ថ្មី) នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក មាត្រា ២០៩ មាត្រា ២១០ មាត្រា ៥០០ មាត្រា ៥០១ មាត្រា ៥០៣ ដល់ មាត្រា ៥០៨ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ ១៩៥៦

បានឃើញពាក្យសុំ ចុះថ្ងៃទី ១៩ ខែមីនា ឆ្នាំ ២០១០ ដែលមេធាវីការពារក្តី អៀង សារី ស្នើឲ្យសហចៅក្រមស៊ើបអង្កេត សុំទៅអង្គបុរេជំនុំជម្រះ ដើម្បីធ្វើមោឃភាពកិច្ចស៊ើបសួរដែលធ្វើឡើងដោយ ឬដោយមានជំនួយពី Stephen Heder និង David Boyle (ពាក្យសុំទីមួយ D381)

បានឃើញពាក្យសុំ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ២០១០ ដែលមេធាវីការពារក្តី ស្នើឲ្យសហចៅក្រមស៊ើបអង្កេត សុំទៅអង្គបុរេជំនុំជម្រះ ដើម្បីធ្វើមោឃភាពឯកសារភស្តុតាងនានាដែលយកចេញពីឯកសារដែលប្រមូលចងក្រងដោយមជ្ឈមណ្ឌលឯកសារកម្ពុជា (ពាក្យសុំទីពីរ D387)

## ការរំលឹកឡើងវិញពីនីតិវិធី និងការកត់សំគាល់របស់មេធាវីការពារក្តី

*ពាក្យសុំមោឃភាពកិច្ចស៊ើបសួរដែលធ្វើឡើងដោយ ឬដោយមានជំនួយពី Stephen Heder និង David Boyle*

១. នៅក្នុងពាក្យសុំទីមួយ មេធាវីការពារក្តីលើកឡើងថា លោក Heder និងលោក David *"មិនមានអនាគតិគ្រប់គ្រាន់ដើម្បីឲ្យជឿទុកចិត្តថាបំពេញកិច្ចស៊ើបសួរដោយគ្មានភាពលំអៀង"* ។ មេធាវីការពារក្តី អះអាងថា *"ក.ស.ច.ស ដឹងអំពីភស្តុតាងនៃភាពលំអៀងរបស់លោក Heder និងលោក David ។ មេធាវីការពារក្តីព្យាយាមជាច្រើនដងដើម្បីទាញចំណាប់អារម្មណ៍ពី ក.ស.ច.ស ទៅលើបញ្ហានេះ។ ទោះជាយ៉ាងណាក៏ដោយក៏ ក.ស.ច.ស មិនបានធ្វើអ្វីទាល់តែសោះ ដើម្បីការពារកុំឲ្យកិច្ចស៊ើបសួរតាមផ្លូវតុលាការជាប់ប្រលាក់ប្រឡូកនឹងភាពលំអៀង។ ផ្ទុយទៅវិញ ក.ស.ច.ស បានបដិសេធមិនឆ្លើយតបទៅនឹងសំណើសុំព័ត៌មាន ហើយពួកគេបានធ្វើគ្រប់មធ្យោបាយដែលស្ថិតនៅក្នុងអំណាចរបស់ពួកគេដើម្បីចៀសវាងមិនលើកពីបញ្ហាលំអៀងនៃការស៊ើបសួររបស់ពួកគេ។"*[1]

២. ដោយផ្អែកលើកត្តាទាំងអស់នេះហើយ ទើបសហមេធាវី ស្នើឲ្យសហចៅក្រមស៊ើបអង្កេត *"សុំទៅអង្គបុរេជំនុំជម្រះ ដើម្បីធ្វើមោឃភាពកិច្ចស៊ើបសួរដែលធ្វើឡើងដោយ ឬដោយមានជំនួយពី Stephen Heder និង David Boyle"*។

*ពាក្យសុំមោឃភាពឯកសារភស្តុតាងនានាដែលយកចេញពីឯកសារដែលប្រមូលបានពីមជ្ឈមណ្ឌលឯកសារកម្ពុជា (DC-Cam)*

៣. នៅក្នុងពាក្យសុំទីពីរ មេធាវីការពារក្តីលើកឡើងថា *"ក.ស.ច.ស មិនបានយកចិត្តទុកដាក់ក្នុងការផ្ទៀងផ្ទាត់មើលពីភាពត្រឹមត្រូវ ភាពអាចទុកចិត្តបាន និងភាពអាចជឿបាននៃភស្តុតាងដែលប្រមូលពី DC-Cam ទេ*។ មេធាវីការពារក្តី លើកឡើងទៀតថា *"ទើបវាត្រូវតែសន្មតថា*

[1] **D381** ពាក្យសុំទីមួយ កថា. ៣៧។

*ក.ស.ច.ស មិនបានធ្វើការខិតខំប្រឹងប្រែង ឬមិនបានបំពេញកិច្ចស៊ើបសួរទាំងឡាយដើម្បីកែតម្រូវ វិការៈនានានៃភស្តុតាងដែលប្រមូលបានពី DC-Cam ឡើយ"*[2] និងបានបន្ថែមថា *"ការប្រើប្រាស់ ភស្តុតាងដែលប្រមូលបានមកពី DC-Cam នៅក្នុងដីកាដំណោះស្រាយ អាចជាការខកខានមិនបាន យកចិត្តទុកដាក់លើសិទ្ធិរបស់លោក អៀង សារី"*[3] ។ ម្យ៉ាងទៀត មេធាវីការពារក្តី មានបំណងថា *" អវតក គួរអនុវត្តតាមគោលការណ៍ណែនាំរបស់ ICTY ស្តីពីការអាចទទួលបាននៃភស្តុតាងដើម្បី ជៀសវាងជំនន់នៃភស្តុតាង ដែលមិនអាចទទួលយកបានដែលត្រូវយកមកពិចារណាសម្រាប់ជា មូលដ្ឋាននៃដីកាចោទប្រកាន់"*[4] ។ ជាចុងក្រោយ មេធាវីការពារក្តី យល់ឃើញថា *"ការចាត់ទុកជា មោឃៈនូវភស្តុតាងដែលប្រមូលបានមកពី DC-Cam ត្រូវតែបានធ្វើនៅពេលនេះ។ សហមេធាវី ការពារក្តី មិនមានឧបាស្រ័យ នៅក្នុងដំណាក់កាលនីតិវិធីពេលក្រោយដើម្បីកែតម្រូវជួសជុល កំហុសវិការៈខាងនីតិវិធីនៅក្នុងកិច្ចស៊ើបសួរតាមផ្លូវតុលាការ ដែលបណ្តាលមកពីការពឹងផ្អែក របស់ កសចស លើភស្តុតាងដែលប្រមូលបានមកពី DC-Cam ឡើយ*[5] ។

៤. ដោយផ្អែកលើកត្តាទាំងអស់នេះហើយ ទើបសហមេធាវី ស្នើឲ្យសហចៅក្រមស៊ើបអង្កេត *"សុំទៅអង្គបុរេជំនុំជម្រះ ដើម្បីធ្វើមោឃភាពឯកសារភស្តុតាងនានាដែលយកចេញពីឯកសារដែល ប្រមូលបានពីមជ្ឈមណ្ឌលឯកសារកម្ពុជា"*។

## សំអាងហេតុនៃសេចក្តីសម្រេច

*ច្បាប់ដែលត្រូវអនុវត្ត*

៥. លើកលែងតែមានការកំណត់ជាមុន ឬមានទម្រង់បែបបទកំណត់ជាមុនច្បាស់ ដែលចែង អំពីមោឃភាព វិការៈខាងនីតិវិធី អាចធ្វើឲ្យមានមោឃភាពកិច្ចមួយ ឬកិច្ចច្រើននៃនីតិវិធី លុះត្រា តែមានការបង្ហាញថា វាមានការរំលោភសិទ្ធិរបស់ជនត្រូវចោទ ដូចដែលមានចែងនៅក្នុង

[2] **D387** ពាក្យសុំទីពីរ កថា. ៣៤។

[3] **D387** ពាក្យសុំទីពីរ កថា. ៤២។

[4] **D387** ពាក្យសុំទីពីរ កថា. ៣៥។

[5] **D387** ពាក្យសុំទីពីរ កថា. ៤៣។

00598436



កាតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងនយោបាយ[6]។ សិទ្ធិទាំងនេះ ត្រូវបានចែងឡើងវិញនៅក្នុងវិធាន ២១ នៃវិធានផ្ទៃក្នុង។

៦. យោងតាមវិធាន ៤៨ នៃវិធានផ្ទៃក្នុង *"កិច្ចស៊ើបសួរ ឬកិច្ចរបស់អង្គជំនុំជម្រះ អាចត្រូវបានចាត់ទុកជាមោឃៈ តែចំពោះករណីមិនគោរពវិធានបញ្ញត្តិដែលធ្វើឲ្យប៉ះពាល់ដល់សិទ្ធិរបស់ភាគីដែលដាក់ពាក្យសុំប៉ុណ្ណោះ។"* ហេតុដូច្នេះ នៅពេលមានសំណើសុំមោឃភាព សហចៅក្រមស៊ើបអង្កេត ត្រូវ៖

- ពិនិត្យមើលពីវត្តមាននៃវិការៈនីតិវិធី និង
- ប្រសិនបើមានវិការៈនីតិវិធី ត្រូវពិនិត្យថាតើវិការៈនេះធ្វើឲ្យប៉ះពាល់ ឬមិនប៉ះពាល់ដល់ផលប្រយោជន៍របស់ភាគីដែលពាក់ព័ន្ធ

ដោយផ្អែកលើគោលការណ៍ទាំងនេះ ទើបចាំបាច់ត្រូវពិនិត្យមើលថាតើបណ្តឹងដែលធ្វើឡើងដោយមេធាវីការពារក្តីនោះត្រឹមត្រូវដែរ ឬទេ?

*ពាក្យសុំទាក់ទិននឹង Stephen Heder និង David Boyle*

៧. សហចៅក្រមស៊ើបអង្កេត សូមបញ្ជាក់ជាបឋមថា ពាក្យសុំមោឃភាពកិច្ចស៊ើបសួរមួយត្រូវតែធ្វើឡើងសំដៅទៅលើកិច្ចនោះឲ្យបានច្បាស់លាស់ និងមិនមែនលក្ខណៈជាបណ្តឹងចិត្តបង្កប់ក្នុងនោះទេ។ ចំពោះករណីនៅពេលនេះ បណ្តឹងជិតចិត្តទៅលើ Stephen Heder និង David Boyle ត្រូវបានធ្វើរួចហើយដោយមេធាវីការពារក្តី និងត្រូវបានបដិសេធចោលមិនទទួលយកដោយអង្គបុរេជំនុំជម្រះហើយដែរ កាលពីថ្ងៃទី ២២ ខែកញ្ញា ឆ្នាំ ២០០៩[7]។ រីឯពាក្យសុំមោឃភាពនាពេលនេះ មិនសំដៅទៅលើកិច្ចណាមួយច្បាស់លាស់ទេ គឺវាគ្រាន់តែជាការវាយប្រហារមួយដែលមានលក្ខណៈបង្វែរដាន ប្រឆាំងនឹងបុគ្គលដដែលៗប៉ុណ្ណោះ តាមរយៈការស្នើសុំមោឃភាពរាល់

---

[6] **D55/I/8** សាលដីកាសម្រេចលើបណ្តឹងឧទ្ធរណ៍របស់ ឌួន ជា ប្រឆាំងនឹងដីកាដែលបដិសេធពាក្យសុំមោឃភាព ចុះថ្ងៃទី ២៦ ខែសីហា ឆ្នាំ ២០០៨ កថា. ៣៤-៤១ ជាពិសេស កថា.៣៦។

[7] សំណុំរឿងរបស់ អៀង សារី ០០២/០៨-០៧-២០០៩-អវតក-អបជ សាលដីកាសម្រេចលើពាក្យបណ្តឹងជិតចិត្តរបស់ជនត្រូវចោទ ចំពោះបណ្ឌិត Stephen Heder និងបណ្ឌិត David Boyle ចុះថ្ងៃទី ២២ ខែកញ្ញា ឆ្នាំ ២០០៩។

00598437



កិច្ចការទាំងអស់របស់ពួកគេដោយចាត់ទុក *"កិច្ចស៊ើបសួរទាំងអស់ដែលធ្វើឡើងដោយលោក Heder និងលោក Boyle ឬដោយមានជំនួយពីអ្នកទាំងពីរជាមោឃៈ*[8] *"*។

៨. ដូចដែលមេធាវីការពារក្តីលើកឡើង សហចៅក្រមស៊ើបអង្កេត បានឆ្លើយតបជាច្រើនលើកច្រើនសាររួចហើយថា ពាក្យសុំបែបនេះ មិនមានមូលដ្ឋានគតិយុត្តទេ គឺវាគ្រាន់តែជាបណ្តឹងដិតចិត្ត[9] ការកំណត់ព្រំដែនការងារ[10] ឬជាការស្នើសុំមោឃភាពកិច្ចរបស់បុគ្គលដែលបានធ្វើជាច្រើនដងរួចហើយ។ ការស្នើសុំដដែលៗ ដែលមិនមានមូលដ្ឋានគតិយុត្ត នឹងមិនទទួលបានផលអ្វីក្រៅពីធ្វើឱ្យការងាររបស់ ក.ស.ច.ស មានការយឺតយ៉ាវប៉ុណ្ណោះ ដែលនាំប៉ះពាល់ដល់កាតព្វកិច្ចរបស់ចៅក្រមស៊ើបអង្កេត ក្នុងការដឹកនាំការស៊ើបសួរបានល្អក្នុងពេលវេលាសមស្រប ដូចដែលមានចែងនៅក្នុងវិធាន ២១(៤) នៃវិធានផ្ទៃក្នុង។

*ពាក្យសុំទាក់ទិននឹងមជ្ឈមណ្ឌលឯកសារកម្ពុជា*

៩. មេធាវីការពារក្តី អះអាងថា *"កសចស មិនបានធ្វើការវិភាគលើវិធីសាស្ត្រដែល DC-Cam បានប្រើប្រាស់សម្រាប់សម្ភាសន៍សាក្សីទាំងឡាយទេ"*[11] និងថា *"ក.ស.ច.ស គ្រាន់តែបានប្រមូលភស្តុតាងពី DC-Cam និងដាក់វាចូលទៅក្នុងសំណុំរឿងប៉ុណ្ណោះ។ ការធ្វើដូច្នេះ ក.ស.ច.ស គ្រាន់តែបានឱ្យអ្នកខាងក្រៅនៅ DC-Cam ជួយការងារស៊ើបអង្កេតរបស់ខ្លួន។ ដូច្នេះអ្នកដែលធ្វើការនៅ DC-Cam បានក្លាយជាអ្នកស៊ើបអង្កេតដោយព្រឹត្តហេតុ"*[12]។ ការចោទប្រកាន់បែបនេះមិនមានមូលដ្ឋានទេ៖ ស.ច.ស ធ្វើប្រតិភូកម្មអំណាចរបស់ខ្លួនតែក្នុងក្របខ័ណ្ឌនៃដីកាចាត់តាំងឱ្យស៊ើបសួរជំនួសដែលមានបទប្បញ្ញត្តកំណត់ច្បាស់លាស់តែប៉ុណ្ណោះ ដូចមានចែងក្នុងវិធាន ៦២ នៃវិធានផ្ទៃក្នុងនៃ អ.វ.ត.ក គឺមិនដូចការចោទប្រកាន់នោះទេ។ ឯកសាររបស់ DC-Cam គឺជាកម្មវត្ថុ

---

[8] **D381** ពាក្យសុំទីមួយ កថា. ២៥។

[9] **A121/III** លិខិតដែលមានចំណងជើងថា "សំណើសុំព័ត៌មាន ស្តីអំពី ទំនាស់ផលប្រយោជន៍ និងភាពលំអៀងទាក់ទិននឹង S. Heder និង D. Boyle ថ្ងៃទី ២៦ ខែ ឧសភា ឆ្នាំ ២០០៨។ **A252/2** លិខិតដែលមានចំណងជើងថា "សំណើសុំព័ត៌មានទាក់ទិននឹង ថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ២០០៩។

[10] **D377/1** លិខិត "ឆ្លើយតប៖ សំណើសុំកំណត់ព្រំដែនការងាររបស់អ្នកស៊ើបអង្កេតនៃ ក.ស.ច.ស ឈ្មោះ S. Heder។"

[11] **D387** ពាក្យសុំទីពីរ កថា. ៣១។

[12] **D387** ពាក្យសុំទីពីរ កថា. ៣៦។

នៃកិច្ចស៊ើបសួររបស់ ក.ស.ច.ស ហើយក្នុងករណីនេះ រហូតទាល់តែមានការស្តាប់ចម្លើយតាមផ្លូវតុលាការដែលមានជាកំណត់ហេតុប៉ុណ្ណោះ ដែលបុគ្គលដែលត្រូវបានសម្ភាសន៍ដោយ DC-Cam អាចទទួលឋានៈជាសាក្សីនៅក្នុងដំណើរការនីតិវិធី។

១០. ទាក់ទិននឹងការទាមទាររបស់មេធាវីការពារក្តីឱ្យអនុវត្តបទដ្ឋាននៃភាពត្រឹមត្រូវតាមច្បាប់នៃភស្តុតាង*តាមការពិនិត្យជាបឋម (prima facie)* ដូចមាននៅក្នុង TIPY[13] នោះ ចាំបាច់ត្រូវធ្វើការបញ្ជាក់ថា សហចៅក្រមស៊ើបអង្កេត មានកាតព្វកិច្ចគោរពវិធាននីតិវិធីដែលមានចែងនៅក្នុងវិធានផ្ទៃក្នុងនៃ អ.វ.ត.ក និងមិនគោរពតាមវិធានដែលអនុវត្តដោយតុលាការផ្សេងទេ។ ម្យ៉ាងទៀត បទដ្ឋាននៃភាពត្រឹមត្រូវតាមច្បាប់នៃភស្តុតាង*តាមការពិនិត្យជាបឋម (prima facie)* ដូចមាននៅក្នុង TIPY នោះ គឺអនុវត្តចំពោះការស៊ើបអង្កេតដាក់បន្ទុកសម្រាប់ធ្វើការចោទប្រកាន់នៅចំពោះមុខ TIPY ដូច្នេះវាផ្ទុយនឹងការស៊ើបសួរដែលស្វែងរកទាំងភស្តុតាងដាក់បន្ទុក និងភស្តុតាងដោះបន្ទុក ដែលធ្វើឡើងដោយ ក.ស.ច.ស របស់ អ.វ.ត.ក។

១១. ជាចុងក្រោយ លើសពីបញ្ហានៃភាពទទួលយកបាននៃភស្តុតាង ការពិតគឺជាបញ្ហាតំលៃនៃភាពជឿបាននៃភស្តុតាងដែលត្រូវបានលើកឡើងដោយមេធាវីការពារក្តី នៅពេលដែលខ្លួនជំទាស់ទៅនឹងតំលៃនៃភាពជឿបានដែល ក.ស.ច.ស យល់ព្រមចំពោះភស្តុតាងទាំងនោះ៖ ដូចនេះមេធាវីការពារក្តី ធ្វើការសន្និដ្ឋានជាទូទៅជាមុនដោយខ្លួនឯង ទាំងពីខ្លឹមសារនៃដីកាដំណោះស្រាយ និងពីការអាចរំលោភសិទ្ធិរបស់ អៀង សារី។ ចរិតលក្ខណៈជារបៀបប៉ាន់ស្មាននៃពាក្យសុំ ធ្វើឱ្យបាត់ភាពអាចទទួលយកបាននៃពាក្យសុំនោះ ដូចអង្គបុរេជំនុំជម្រះ បានសម្រេចលើពាក្យបណ្តឹងដែលមានលក្ខណៈស្រដៀងគ្នានេះ ដោយកត់សំគាល់ថា៖ *"ការចោទសួររបស់សហមេធាវីការពារក្តីទៅលើបំណងរបស់ ក.ស.ច.ស ខ្លួនពឹងផ្អែកលើផ្នែកណាខ្លះក្នុងសំណុំរឿង មិនទាន់ដល់ពេលនៅឡើយទេនៅក្នុងដំណាក់កាលនេះនៃដំណើការនីតិវិធី"* [14] ។ លើសពីនេះទៀត ទឡ្ហីករណ៍ដែលមេធាវីការពារក្តីលើកឡើងថា ខ្លួនមិនអាចជំទាស់នឹងតំលៃនៃភស្តុតាងបន្ទាប់ពីការចេញដីកាដំណោះស្រាយនោះ គឺជាការយល់ខុស ពីព្រោះ ដូចដែលអង្គបុរេជំនុំជម្រះបានបញ្ជាក់រួចហើយថា *"ប្រសិនបើដើមបណ្តឹងឧទ្ធរណ៍ពិតជាមានមន្ទិលសង្ស័យលើយថាភាពនៃភស្តុតាងដែលក.ស.ច.ស*

[13] **D387** ពាក្យសុំទីពីរ កថា. ៣៥។

[14] **D253/3/5** សាលដីកាសម្រេចលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីការបស់ សចស សម្រេចលើសំណើសុំបំពេញកិច្ចស៊ើបសួរលើកទី ១៦ (D253)និងលើកទី ១៧ (D265)របស់ នួន ជា ថ្ងៃ ៦ ខែមេសា ឆ្នាំ ២០១០ កថា. ១២។

*យកមកធ្វើជាមូលដ្ឋានដើម្បីចេញដីកាដំណោះស្រាយ ដោយសារតែប្រភព និង/ឬប្រព័ន្ធនៃការរក្សាទុកភស្តុតាងទាំងនោះ ដើមបណ្តឹងឧទ្ធរណ៍ នៅតែមានឱកាសដើម្បីជំទាស់តវ៉ាលើយថាភាពនៃភស្តុតាងទាំងនោះ នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងបានដដែល"*[15] ។

១២. ដោយផ្អែកទៅលើកត្តាទាំងអស់នេះ មិនមានអ្វីដែលអាចធ្វើជាយុត្តិកម្មដើម្បីសុំទៅអង្គបុរេជំនុំជម្រះ ឱ្យសម្រេចមោឃភាពទេ៖ អាស្រ័យដោយមិនមានវិការៈនៃនីតិវិធីណាមួយនោះ មិនមានសិទ្ធិណាមួយរបស់មេធាវីការពារក្តី ដែលមានចែងនៅក្នុងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងនយោបាយ ឬមានចែងក្នុងវិធាន ២១ នៃវិធានផ្ទៃក្នុង ត្រូវបានរំលោភទេ ហេតុនេះពាក្យសុំទាំងពីរបានត្រឹមតែបដិសេធចោលប៉ុណ្ណោះ។

**ហេតុដូច្នេះ សហចៅក្រមស៊ើបអង្កេត**

**សម្រេច** មិនស្នើសុំទៅអង្គបុរេជំនុំជម្រះដើម្បីធ្វើមោឃភាពទេ។
**បដិសេធ** ពាក្យសុំ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៣ ខែកញ្ញា ឆ្នាំ ២០១០

**សហចៅក្រមស៊ើបអង្កេត**
**Co-Investigating Judges**
**co-juges d'instruction**

**Marcel LEMONDE**

យូ ប៊ុនឡេង

---

[15]**D253/3/5** សាលដីកាសម្រេចលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីការបស់ សចស សម្រេចលើសំណើ សុំបំពេញកិច្ចស៊ើបសួរលើកទី ១៦ (D253) និងលើកទី ១៧ (D265) របស់ នួន ជា ថ្ងៃ ៦ ខែមេសា ឆ្នាំ ២០១០ កថា. ១៣។